# គណបក្ស សម រង្ស៊ី

**SAM RAINSY PARTY**
**PARTI SAM RAINSY**
**សីលធម៌ សច្ចធម៌ យុត្តិធម៌**

# សេចក្តីថ្លែងការណ៍

**គណបក្ស សម រង្ស៊ី** សម្តែងការសោកស្តាយយ៉ាងខ្លាំងចំពោះការបង្ក្រាបដោយហិង្សាពីសំណាក់កងកម្លាំងនគរបាល និងកងរាជអាវុធហត្ថ ទៅលើបងប្អូនកម្មករ-កម្មការិនីប្រមាណ ៣០០០នាក់ ដែលបានធ្វើកូដកម្ម នៅមុខរោងចក្រកាត់ដេរ PCCS ដើម្បីសុំឲ្យថៅកែរោងចក្រ ទទួលយកលោកស្រី **ម៉ន ចាន់ណា** ជាតំណាងសហជីពសេរីកម្មករប្រចាំនៅរោងចក្រនេះ ឲ្យចូលបំរើការងារវិញ កាលពីព្រឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ ។

ការប្រើអំពើហិង្សាមកលើកូដករបែបនេះ គឺជាទង្វើរំលោភបំពានយ៉ាងធ្ងន់ធ្ងរមកលើសិទ្ធិបុគ្គល និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់របស់កម្មករ-កម្មការិនី ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ។

**គណបក្ស សម រង្ស៊ី** សូមគាំទ្រចំពោះការធ្វើកូដកម្មដោយអហិង្សារបស់បងប្អូនកម្មករ-កម្មការិនី នៃរោងចក្រកាត់ដេរ PCCS ដើម្បីទាមទារ និងរកយុត្តិធម៌ជូនតំណាងរបស់ខ្លួនដែលត្រូវបានថៅកែរោងចក្រ បញ្ឈប់ពីការងារយ៉ាងអយុត្តិធម៌ ។

ជាថ្មីម្តងទៀត **គណបក្ស សម រង្ស៊ី** សូមថ្កោលទោសចំពោះការប្រើអំពើហិង្សាមកលើបងប្អូនកម្មករ-កម្មការិនី នៃរោងចក្រកាត់ដេរ PCCS និងសូមអំពាវនាវឲ្យអាជ្ញាធរមានសមត្ថកិច្ច និងថៅកែរោងចក្រកាត់ដេរ PCCS ធ្វើការដោះស្រាយយ៉ាងណាឲ្យលោកស្រី **ម៉ន ចាន់ណា** ជាតំណាងសហជីពសេរីកម្មករ បានចូលបំរើការងារនៅក្នុងរោងចក្រនេះវិញ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០*

**អគ្គលេខាធិការដ្ឋានគណបក្ស**

* ព័ត៌មានបន្ថែម សូមទាក់ទង : ០១២ ៧៨៨ ៩៩៩

**ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphq@online.com.kh, srpcabinet@online.com.kh, Website : samrainsyparty.org